# ជំនួយស្មារតី

## ស្តីពីកិច្ចសហប្រតិបត្តិការឆ្នាំកម្ពុជា-ឡាវ ឆ្នាំ២០២៤
## សម្រាប់កិច្ចប្រជុំ SOMTC នៅទីក្រុងវៀងចន្ទន៍
## ចាប់ពីថ្ងៃទី២៦-២៨ ខែមិថុនា ឆ្នាំ២០២៤

## I. អំពីថ្នាក់ដឹកនាំសំខាន់ៗ

- **ប្រធានរដ្ឋ** : ឯកឧត្តមបណ្ឌិត **ថងលុន ស៊ីសុលីត** (កាន់តំណែងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ និងកាន់តំណែងជាអគ្គលេខាធិការបក្ស ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១)
- **នាយករដ្ឋមន្ត្រី** : ឯកឧត្តមបណ្ឌិត **សនសៃ ស៊ីផាន់ដន** (កាន់តំណែងថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២)
- **ប្រធានរដ្ឋសភាជាតិ** : ឯកឧត្តម **សៃស៊ុមផន ភុមវិហាន** (កាន់តំណែងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១)
- **រដ្ឋមន្ត្រីការបរទេស** : ឯកឧត្តម **សាលើមសៃ គុំម៉ាស៊ីត** (កាន់តំណែងថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ និងកាន់តំណែងសម្រាប់អាណត្តិទី២ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ និងត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រី នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២)

## II. ទំនាក់ទំនងការទូត

- **នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥៦ ៖** កម្ពុជា-ឡាវ បានភ្ជាប់ទំនាក់ទំនងការទូត។
- **នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ៖** ខួបលើកទី៦៥ ថ្ងៃបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ។
- **ឯកអគ្គរាជទូត/រដ្ឋទូត**
  - **ឯកអគ្គរាជទូតកម្ពុជាប្រចាំឡាវ ៖ ឯកឧត្តម ហ៊ុលក្រុង ផាណាង** បានជូនសារតាំងនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣។
  - **ឯកអគ្គរដ្ឋទូតឡាវប្រចាំកម្ពុជា ៖ ឯកឧត្តម ប្លូកែវ ភូមិវង្សសៃ** បានជូនសារតាំង នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។

❖ ស្ថានអគ្គកុងស៊ុល

– នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ កម្ពុជាបានសម្ពោធស្ថានអគ្គកុងស៊ុលជាផ្លូវការនៅទីក្រុងប៉ាក់សេ ខេត្តចម្ប៉ាសាក់។ លោក **គី មុនីរ័ត្ន** អគ្គកុងស៊ុល បានលិខិតទទួលស្គាល់ពី ក្រសួងការបរទេសឡាវ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣។

– នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ឡាវបានសម្ពោធស្ថានអគ្គកុងស៊ុលជាផ្លូវការនៅខេត្តស្ទឹងត្រែង។ លោកអគ្គកុងស៊ុល ***កែវ វង្សសៃ*** បានលិខិតទទួលស្គាល់ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣។

## III. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

❖ **ទំនាក់ទំនងពាណិជ្ជកម្ម**

| ទំនិញ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | ឆ្នាំ២០២៣ |
|---|---|---|---|---|
| កម្ពុជានាំចេញទៅឡាវ | USD ១.៣ លាន | USD ២.៧២ លាន | USD ២.៦០ លាន | USD ៤.០៦ លាន |
| កម្ពុជានាំចូលពីឡាវ | USD ១០៣.០១ លាន | USD ១៥៨.០៩ លាន | USD ២០៨.១៤ លាន | USD ១៩០.២៦ លាន |
| សរុបៈ | **USD ១០៤.៣១ លាន** | **USD ១៦០.៨១ លាន** | **USD ២១០.៧៥ លាន** | **USD ១៩៤.៣៣ លាន** |
| (ប្រភពៈ ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | | | | |

❖ **ទេសចរណ៍ (ភ្ញៀវអន្តរជាតិចូលមកកម្ពុជា តាមរយៈប្រទេសឡាវ)**

| | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | ៦ខែ ឆ្នាំ២០២៣ |
|---|---|---|---|---|---|
| កម្ពុជាទៅឡាវ | ២៨,៣៤២ នាក់ | ៥,០១២ នាក់ | មិនទាន់មានទិន្នន័យ | ១១,៥៤៣ នាក់ | ៩,២៩៥ នាក់ |
| ឡាវមកកម្ពុជា | ៣៦៣,៩៥១ នាក់ | ៣៤,៣៤៥ នាក់ | ២៨២ នាក់ | ៩២,៦០៩ នាក់ | ៣៣០,៧២៤ នាក់ |
| (ប្រភពៈ ក្រសួងទេសចរណ៍កម្ពុជា) | | | | | |

## IV. កិច្ចសហប្រតិបត្តិការបង្ក្រាបបទល្មើស (ក្នុងឆ្នាំ២០២៣)

❖ **បទល្មើសគ្រឿងញៀន (ព្រំដែនកម្ពុជា-ឡាវ)**

– សមត្ថកិច្ចកម្ពុជា បានទប់ស្កាត់ និងបង្ក្រាបជាឯកតោភាគីចំនួន **០៥ករណី** ឃាត់ខ្លួនចំនួន **០៨នាក់** (ជនជាតិឡាវចំនួន **០៣នាក់** វៀតណាម **០១នាក់** ចិន **០២នាក់** និងថៃ **០២នាក់**) និងវត្ថុតាងរួមមានៈ សារធាតុញៀន ប្រភេទ ICE ទម្ងន់ ៦២១គីឡូក្រាម ៥៣៩.៦០ក្រាម និងសារធាតុញៀនប្រភេទ KETAMINE ទម្ងន់ ៧៨៩គីឡូក្រាម ៧៨១ក្រាម រថយន្តចំនួន ០២គ្រឿង ទូរសព្ទដៃ ០២គ្រឿង ម៉ូតូ ០៣គ្រឿង ប្រាក់ឡាវចំនួន ៧៦,០០០គីប លិខិតឆ្លងដែនឡាវចំនួន ០១ក្បាល អត្តសញ្ញាណបណ្ណឡាវ ០១សន្លឹក កាត ATM ០៣សន្លឹក។ ជនសង្ស័យ និងវត្ថុតាងត្រូវបានបញ្ជូនទៅសាលាដំបូងខេត្តស្ទឹងត្រែង និងសាលាដំបូងរាជធានីភ្នំពេញ។

- **បទល្មើសអន្តោប្រវេសន៍**
  - នៅក្នុងឆ្នាំ២០២៣ ភាគីទាំងពីរបានសហការបញ្ជូន៖
    - ភាគីកម្ពុជា បានបញ្ជូនពលរដ្ឋឡាវឆ្លងដែនខុសច្បាប់ចំនួន ០៤នាក់ (ស្រី ០១នាក់)។
    - ភាគីឡាវ បានបញ្ជូនពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ចំនួន ០២នាក់។
- **កិច្ចប្រជុំផ្លាស់ប្តូរសភាពការណ៍**
  - អាជ្ញាធរ និងកងកម្លាំងសមត្ថកិច្ចនៃប្រទេសទាំងពីរបានជួបប្រជុំប្តូរវេន ដើម្បីផ្លាស់ប្តូរសភាព-ការណ៍ចំនួន **២១លើក** ក្នុងនោះ៖ ថ្នាក់ខេត្តចំនួន ០៤លើក ថ្នាក់វរសេនាតូចចំនួន ០៣លើក ថ្នាក់ប៉ុស្តិ៍ចំនួន ១២លើក និងរួមគ្នាដោះស្រាយបញ្ហាផ្សេងៗចំនួន ០២លើក។

## V. កិច្ចសហប្រតិបត្តិការការងារគ្រប់គ្រងព្រំដែន

- **សភាពការណ៍ និងបាតុភាពផ្សេងៗតាមបណ្តោយព្រំដែន**
  - ក្នុងឆ្នាំ២០២៣កន្លងទៅនេះ សមត្ថកិច្ចកម្ពុជាបានធ្វើការដើរល្បាតត្រួតពិនិត្យសភាពការណ៍តាមខ្សែបន្ទាត់ព្រំដែនជាឯកតោភាគីចំនួន **៤៩៧លើក** ក្នុងនោះ៖
    - ម្ចាស់ការល្បាតចំនួន ៤២៣លើក។
    - សហការល្បាតជាមួយកងកម្លាំងយោធពលខេមរភូមិន្ទចំនួន ៧៤លើក។
  - ទន្ទឹមនេះ ភាគីឡាវបានធ្វើសកម្មភាពមិនប្រក្រតីចំនួន **០៣លើក** ដូចខាងក្រោម៖
    - ភាគីឡាវបានយកគ្រឿងចក្រមកឈូសឆាយផ្លូវប្រវែង ១០០ម នៅខាងកើតច្រកអន្តរជាតិត្រពាំងគ្រៀល ខេត្តស្ទឹងត្រែង។
    - ជនមិនស្គាល់អត្តសញ្ញាណបានលួចដកចោលបង្គោលបំពេញបន្ថែម លេខ០៣៤.១។
    - ជនមិនស្គាល់អត្តសញ្ញាណបានលួចដកបង្គោលសាក្សីដែលហ៊ុំព័ទ្ធបង្គោលលេខ ៤១ ចំនួន ០៣បង្គោល។
  - នៅក្នុងជំនួបទ្វេភាគី នៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីរវាងក្រសួងមហាផ្ទៃកម្ពុជា ក្រសួងសន្តិសុខសាធារណៈឡាវ និងក្រសួងនគរបាលវៀតណាម នាទីក្រុងដាណាំងកាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ ភាគីកម្ពុជាបានស្នើភាគីឡាវផ្តល់កិច្ចសហការ និងសម្របសម្រួលដល់កងកម្លាំងនគរបាល និងយោធាតាមតំបន់ព្រំដែន ចុះពង្រឹងការត្រួតពិនិត្យចំណុចអសកម្មផ្សេងៗតាមតំបន់ព្រំដែន និងមានការប្រើប្រាស់ដ្រូនផងដែរ ដើម្បីសម្រួលដល់ការងារនេះ ដោយមិនធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យរបស់ភាគឡាវទេ។ ភាគីឡាវបានឯកភាព និងស្នើកម្ពុជាជូនដំណឹងដល់ភាគីឡាវជាមុន។
- **ការងារបោះបង្គោលខណ្ឌសីមា**
  - ក្នុងឆ្នាំ២០២៣ ក្រុមការងារបច្ចេកទេសចម្រុះបានចុះវាស់វែងខណ្ឌសីម៉ា និងបោះបង្គោលព្រំដែនបណ្តោះអាសន្នចំនួន ៤៤បង្គោល។

- នៅក្នុងជំនួបទ្វេភាគី នៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីរវាងក្រសួងមហាផ្ទៃកម្ពុជា ក្រសួងសន្តិសុខសាធារណៈឡាវ និងក្រសួងនគរបាលវៀតណាម នាទីក្រុងដាណាំងកាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ ឯកឧត្តម អភិសន្តិបណ្ឌិត **ស សុខា** និង ឯកឧត្តម នាយឧត្តមសេនីយ៍ **វិល័យ ឡាខាំហ្វង** បានឯកភាពគ្នាជំរុញការងារខណ្ឌសីមា ដើម្បីកុំឱ្យបញ្ហាព្រំដែនក្លាយជាជំងឺរ៉ាំរ៉ៃ។

❖ **ដំណើរចេញ-ចូលព្រះរាជាណាចក្រកម្ពុជា**

គិតក្នុងរយៈពេល ៥ខែ ឆ្នាំ២០២៤ កន្លងទៅនេះ ជនជាតិឡាវបាន៖

- ដំណើរចូលសរុបចំនួន **១៧១,១៣៨នាក់** កើនឡើងចំនួន **១១០,៤៦៤នាក់** ស្មើនឹង **៥៤.៩៣%**។
- ដំណើរចេញសរុបចំនួន **១៦៩,៨៥៥នាក់** កើនឡើងចំនួន **១៥៦,៥១៧នាក់** ស្មើនឹង **៨.៥២%**។

**កត់សំគាល់៖**

- បច្ចុប្បន្ននេះ មាននិស្សិតខ្មែរកំពុងបន្តការសិក្សានៅប្រទេសឡាវចំនួន **៩៦នាក់** និងនិស្សិតឡាវកំពុងបន្តការសិក្សានៅប្រទេសកម្ពុជាចំនួន **៨៨នាក់**។
- ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ ក្រសួងមហាផ្ទៃកម្ពុជា បានបញ្ជូនសិក្ខាកាម ចំនួន ០៤នាក់ (បច្ចុប្បន្ន កំពុងសិក្សាឆ្នាំទី៤ ចំនួន ០២នាក់ និងឆ្នាំទី១ ចំនួន ២នាក់) និងទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ៣.៧លានគីប/១ខែ (ស្មើនឹងប្រមាណ ១៧៦ ដុល្លារអាមេរិក)។
- ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ ក្រសួងសន្តិសុខសាធារណៈឡាវ បានបញ្ជូនសិក្ខាកាម ចំនួន ០៤នាក់ (បច្ចុប្បន្ន កំពុងសិក្សាឆ្នាំទី៤ ចំនួន ០២នាក់ និងឆ្នាំទី១ ចំនួន ២នាក់)។
- កន្លងមកនេះ ភាគីឡាវបានស្នើដោះស្រាយបញ្ហាប្រឈមមួយចំនួន ពាក់ព័ន្ធនឹងបញ្ហាទិដ្ឋាការស្នាក់នៅកំពុងស្នាក់នៅកម្ពុជា និងការផ្តល់ប្រាក់អាហារូបករណ៍ប្រចាំខែ។
- ករណីនេះ ក្រសួងមហាផ្ទៃ ក៏បានធ្វើលិខិតអន្តគមន៍ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងណែនាំអង្គភាពពាក់ព័ន្ធក្រោមចំណុះ ឱ្យដោះស្រាយជូននិស្សិតឡាវរួចហើយ។
- ចំពោះនិស្សិតឡាវកំពុងសិក្សាឆ្នាំទី៤ បានទទួលប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ២១០ដុល្លារ១/ខែ និងនិស្សិតឡាវកំពុងសិក្សាឆ្នាំទី១ បានទទួលប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ១៨០ដុល្លារ/១ខែ និងប្រាក់ឧបត្ថម្ភផ្សេងទៀតចំនួន ២០ដុល្លារ/ឆ្នាំ។

## VI. លទ្ធផលការអនុវត្តកំណត់ហេតុឆ្នាំ២០២៣

| | **លទ្ធផលអនុវត្តបានក្នុងឆ្នាំ២០២៣** | |
|---|---|---|
| **ការផ្លាស់ប្តូរគណៈប្រតិភូ** | កម្ពុជាត្រូវបញ្ជូនចំនួន ០៤ប្រតិភូ (អនុវត្តបាន ០១ប្រតិភូ) | ឡាវត្រូវបញ្ជូនចំនួន ០៥ប្រតិភូ (អនុវត្តបាន ០២ប្រតិភូ) |
| **ការបណ្តុះបណ្តាលធនធានមនុស្ស** | កម្ពុជាបានបញ្ជូន ០២រូប (បានអនុវត្ត) | ឡាវបានបញ្ជូន ០២រូប (បានអនុវត្ត) |

## VII. រាជធានី-ខេត្តចងសម្ព័ន្ធមេត្រីភាព

| ល.រ | រាជធានី-ខេត្ត កម្ពុជា | ខេត្ត/ក្រុង ឡាវ | ខ្លឹមសារ | កាលបរិច្ឆេទ |
|---|---|---|---|---|
| ១ | ខេត្តសៀមរាប | ខេត្តចំប៉ាសាក់ | អនុស្សរណៈនៃការយោគយល់គ្នា | ២០១១ |
| ២ | រាជធានីភ្នំពេញ | ទីក្រុងវៀងចន្ទន៍ | កិច្ចព្រមព្រៀងស្តីពីការបង្កើតទំនាក់ទំនងសម្ព័ន្ធមេត្រីភាពរវាងរាជធានីភ្នំពេញនិងទីក្រុងវៀងចន្ទន៍ | ២០១៤ |
| ៣ | ខេត្តស្ទឹងត្រែង | ១.ខេត្តចំប៉ាសាក់ | កំណត់ហេតុកិច្ចប្រជុំទ្វេភាគី | ឆ្នាំ២០១៩ |
| | | ២.ខេត្តអត្តពឺ | កំណត់ហេតុកិច្ចប្រជុំទ្វេភាគី | ឆ្នាំ២០១៩ |

## VIII. ជនជាតិឡាវជាប់ឃុំនៅកម្ពុជា

- គិតត្រឹមថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ជនជាតិឡាវកំពុងជាប់ឃុំនៅកម្ពុជា សរុបចំនួន **៤២នាក់** (ស្រីចំនួន ០០នាក់)៖
  - ទណ្ឌិត **១១នាក់**
  - ពិរុទ្ធជន **២៩នាក់**
  - ជនត្រូវចោទ **០១នាក់**
  - ជនជាប់ចោទ **០១នាក់**។
- បានសហការជាមួយក្រសួងយុត្តិធម៌ តំណាងស្ថានទូតឡាវ និងអាជ្ញាធរពាក់ព័ន្ធក្នុងការផ្ទេរទណ្ឌិតជនជាតិឡាវចំនួន **៣៤នាក់ (ស្ត្រី ០៣នាក់)**។

## IX. បញ្ហាប្រឈមផ្សេងៗ

- ភូមិសាស្ត្រស្មុគស្មាញ កង្វះហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ចំណេះដឹងប្រជាពលរដ្ឋនៅមានកម្រិត កង្វះមធ្យោបាយផ្តល់ព័ត៌មានទៅវិញទៅមក បង្កការលំបាកដល់កងកម្លាំងមានសមត្ថកិច្ចក្នុងការល្បាត បង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសផ្សេងៗ ជាពិសេសបទល្មើសគ្រឿងញៀន។
- ការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក ការទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ និងការអប់រំប្រជាពលរដ្ឋ នៃប្រទេសទាំងពីរ មិនទាន់បានអនុវត្តទូលំទូលាយ ដែលជាហេតុនាំឱ្យមានបញ្ហាពាក់ព័ន្ធដល់ការអនុវត្តន៍បទប្បញ្ញត្តិព្រំដែន។
- សកម្មភាពទំនាក់ទំនងសហប្រតិបត្តិការរវាងការិយាល័យ BLO នៃប្រទេសទាំងពីរមិនទាន់ស៊ីចង្វាក់គ្នា ដែលជាផ្នែកមួយនៃការខ្វះខាតក្នុងការផ្លាស់ប្តូរព័ត៌មានឱ្យគ្នា ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពបទល្មើសគ្រឿងញៀន។

## X. ទិសដៅ និងសំណូមពរ

ក្រសួងមហាផ្ទៃ សូមស្នើភាគីឡាវ ដូចតទៅ៖

- ជំរុញយន្តការដែលមានស្រាប់ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មានបម្រើឱ្យការងារជំនាញ និងការងារប្រឆាំងបទល្មើស។
- ភាគីទាំងពីរយកចិត្តទុកដាក់បង្កើនការអប់រំប្រជាពលរដ្ឋ ដែលរស់នៅតាមបណ្តោយព្រំដែនប្រទេសទាំងពីរឱ្យបានយល់ដឹងពីបទប្បញ្ញត្តិព្រំដែន ក៏ដូចជាការយល់ដឹងពីល្បិចកលពួកឧក្រិដ្ឋជន ឬជនល្មើសដើម្បីបណ្តុះមនសិការ និងលើកកម្ពស់ស្មារតីប្រជាពលរដ្ឋ នៃប្រទេសទាំងពីរឱ្យចេះគោរពច្បាប់ និងចូលរួមចំណែកក្នុងការរក្សាសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួនព្រមទាំងសហគមន៍។
- បន្តយកចិត្តទុកដាក់ផ្លាស់ប្តូរព័ត៌មាន ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ឧបាយកល ល្បិចកល និងសកម្មភាពរបស់បណ្តាអានុភាពអមិត្ត ដែលមានបំណងបំផ្លិចបំផ្លាញសន្តិសុខជាតិ ក៏ដូចជាចំណងសាមគ្គីភាព មិត្តភាពរវាងប្រទេសទាំងពីរ ជាពិសេសបន្តសហការទប់ស្កាត់រាល់សកម្មភាពរបស់ក្រុមជ្រុលនិយម ដែលប៉ុនប៉ងបង្កអសន្តិសុខនៅតាមតំបន់ព្រំដែនប្រទេសទាំងពីរ។
- បង្កើនកិច្ចសហប្រតិបត្តិការ បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពនៅតាមតំបន់ព្រំដែនប្រទេសទាំងពីរ។

- បន្តរួមសហការការពារសន្តិសុខ និងបង្កលក្ខណៈងាយស្រួល ដល់គណៈកម្មាធិការចំរុះត្រួតពិនិត្យខណ្ឌសីមា និងបោះបង្គោលព្រំដែនកម្ពុជា-ឡាវ ដើម្បីរួមចំណែកអនុវត្តផែនការរបស់រដ្ឋាភិបាលនៃប្រទេសទាំងពីរបានសម្រេចតាមការកំណត់។
- បង្កើនសកម្មភាពត្រួតពិនិត្យ គ្រប់គ្រងព្រំដែនតាមដែនសមត្ថកិច្ចរបស់ភាគីនីមួយៗ និងចាត់វិធានការទាន់ពេលវេលា ក្នុងការទប់ស្កាត់នូវរាល់បទល្មើសគ្រប់ប្រភេទ ដោយជំរុញសកម្មភាពល្បាតទប់ស្កាត់នូវរាល់បទល្មើសព្រៃឈើ ការទន្ទ្រានកាប់ព្រៃធ្វើការដាំដុះ និងការបរបាញ់សត្វ ដោយខុសច្បាប់ និងសកម្មភាពនានាដែលបំពានបទប្បញ្ញត្តិព្រំដែន ជាពិសេស បទល្មើសគ្រឿងញៀន។

# ប្រវត្តិរូបសង្ខេប



I. **ព័ត៌មានផ្ទាល់ខ្លួន**

- នាមខ្លួន និងនាមត្រកូល : ស៊ុឡៈណៈ កែវបៈស៊ើត
- ឋានន្តរស័ក្តិ : ឧត្តមសេនីយ៍ទោ
- ថ្ងៃខែឆ្នាំកំណើត : ១៨ មេសា ១៩៧៤
- ទីកន្លែងកំណើត : ខេត្តហួផាន់ ប្រទេសឡាវ
- ស្ថានភាពគ្រួសារ : បានរៀបការ មានកូន ០៤នាក់ (ស្រី០២នាក់ ប្រុស០២នាក់)

II. **ប្រវត្តិការសិក្សា**

- ឆ្នាំ ២០០៣-២០០៥ : បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញវិទ្យាសាស្ត្រនគរបាល នៅបណ្ឌិត្យសភានគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម
- ភាសាបរទេស : ភាសាវៀតណាម

III. **បទពិសោធន៍ការងារ**

- ឆ្នាំ២០២០-២០២២ : នាយករងខុទ្ទកាល័យក្រសួងសន្តិសុខសាធារណៈឡាវ
- ២០២៣- បច្ចុប្បន្ន: នាយកខុទ្ទកាល័យក្រសួងសន្តិសុខសាធារណៈឡាវ